ព្រះរាជក្រម

នស/រកម/០៦១៣/០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវដ្ឋរាស្ត្រ ឥទ្ធិន្ទ្រាធរមហាឥស្សរ
ខេមរាជនា សម្ភហោភាស តម្ពុជឯករាជវដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងតម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ទិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

មាត្រា មួយ.-

មាត្រា២៤៧ (ដីកាដំណោះស្រាយ) មាត្រា៣៦៨ (រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់) មាត្រា៣៧២ (បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី) និងមាត្រា៣៨២ (រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា ២៤៧ថ្មី.- ដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ ។

ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទល្មហ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ ៖

១- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទល្មហ ។

២- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។

៣- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

៤- ករណីដែលបណ្តឹងអាជ្ញារលត់ ។

ដីកាដំណោះស្រាយជានិច្চកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវដាប់កាតព្វកិច្চគោរពតាមដីកាសន្និដ្ឋានស្តាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួរឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួរកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុនឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថាឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការនិងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

មាត្រា ៣៦៨ថ្មី.- រយៈពេលសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត ៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំចាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាម

បទប្បញ្ញត្តិដែលមានចែងក្នុងគន្លឹទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

មាត្រា ៣៧២ថ្មី.- បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្តឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។

បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្លឹទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

បណ្តឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិសោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្តឹងទាស់ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកទៅអនុវត្តលើបុគ្គលដែលតុលាការប្រកាសថា ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ។

Ksl

មាត្រា ៣៨ថ្មី.- រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលផុតកំណត់ប្តឹងទាស់ ។

មាត្រាពីរ.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ការ.១៣០៤.៦៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អន្ត ឥន្ទ្រ ឥន្ទ្រានា

លេខ: ៥៩៣ស.ណ

សំណៅថតចម្លងត្រឹមត្រូវជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣

អគ្គលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល